00721786

E100/3

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អវតក- (អ.ជ.ស.ប.) |
| ភាគីដាក់ឯកសារ: | លោក ខៀវ សំផន |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | **បារាំង** |
| កាលបរិច្ឆេទឯកសារ: | ២២ កក្កដា ២០១១ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 07 / 2011
ម៉ោង (Time/Heure) : 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ប៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី៣ នៃសមាគមគ្រិស្តកម្ពុជា**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ |
|---|---|
| **សហមេធាវីការពារក្តីលោក ខៀវ សំផន** | **អង្គបុរេជំនុំជម្រះ** |
| លោក ស សូវាន | ចៅក្រម និល ណុន |
| លោក Jacques VERGES | ចៅក្រម ធូ មណី |
| | ចៅក្រម យ៉ា សុខន |
| **អ្នកជំនួយការ** | ចៅក្រម Jean-Marc LAVERGNE |
| លោកស្រី សេង សុជាតា | ចៅក្រម Silvia CARTWRIGHT |

លោកស្រី Marie CAPOTORTO

លោក Shéhérazade BOUARFA

លោក Mariette SABATIER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី Elisabeth SIMONNEAU FORT

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ លោក ខៀវ សំផន បានដាក់បណ្តឹងឧទ្ធរណ៍មួយប្រឆាំងទៅនឹងដីកាសម្រេចលើការដាក់ឱ្យអនុវត្តទម្រង់នៃការទទួលខុសត្រូវ ហៅថា "សហឧក្រិដ្ឋកម្មរួម"[1] នៅ អ.វ.ត.ក.។

២. កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០ បន្ទាប់ពីអង្គជំនុំជម្រះបានទទួលសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ[2] របស់ខ្លួនរួចមក សហព្រះរាជអាជ្ញាបានដាក់នូវចម្លើយតបរបស់ខ្លួន[3]។

៣. នៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១០ លោក ខៀវ សំផន បានដាក់ចម្លើយឆ្លើយតបរបស់ខ្លួន[4]។

៤. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីអំពីសហឧក្រិដ្ឋកម្មរួម ដែលតាមរយៈសេចក្តីសម្រេចនោះ អង្គបុរេជំនុំជម្រះបានវិនិច្ឆ័យថា សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី៣ មិនអាចត្រូវបានប្រកាន់យកថាជាទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខ អ.វ.ត.ក. ឡើយ[5]។

---

[1] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការដាក់ឱ្យអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថា "សហឧក្រិដ្ឋកម្មរួម", ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ *ឯកសារតុលាការ* D97/16/1។

[2] សេចក្តីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ របស់សហព្រះរាជអាជ្ញាក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ, ខៀវ សំផន, អៀង សារី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនប្រឆាំងនឹងដីកាសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១០ *ឯកសារតុលាការ* D97/16/4។

[3] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០ *ឯកសារតុលាការ* D97/16/5 ។

[4] ចម្លើយរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន តបនឹងចម្លើយរួមរបស់សហព្រះរាជអាជ្ញា លើសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១០ *ឯកសារតុលាការ* D97/16/9។

[5] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ *ឯកសារតុលាការ* D97/14/15 ("សាលដីការបស់អង្គបុរេជំនុំជម្រះ")។

៥. កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ លោក ខៀវ សំផន បានដាក់នូវអញ្ញត្រកម្មបឋមរបស់ខ្លួន ដែលតាមរយៈនោះ លោក ខៀវ សំផន បានជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះទៅលើករណីនៃសហឧក្រិដ្ឋកម្មរួម ក្រោមគ្រប់ទម្រង់ទាំងអស់[6]។

៦. កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់នូវចម្លើយតបតែមួយរបស់ខ្លួនទៅនឹងអញ្ញត្រកម្មបឋម[7]។

៧. កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយហេតុថាជនជាប់ចោទបានចូលរួមទៅក្នុងទម្រង់ទី ៣ នៃសហឧក្រិដ្ឋកម្មរួម[8]។ អង្គជំនុំជម្រះបានទុកពេលវេលាឱ្យក្រុមមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី ដាក់ចម្លើយតបរបស់ខ្លួនរហូតដល់ថ្ងៃទី ២២ ខែ កក្កដា[9]។

៨. កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ លោក អៀង សារី បានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចបន្ទាន់មួយ ពាក់ព័ន្ធទៅនឹងភាពដែលអាចទទួលយកបាននៃសំណើសុំនេះ (ក្នុងចំណោមសំណើសុំឯទៀត) ក្នុងដំណាក់កាលនៃនីតិវិធីនេះ[10]។

---

[6] អញ្ញត្រកម្មបឋមលើយុត្តាធិការ, ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ *ឯកសារតុលាការ* E46 ("អញ្ញត្រកម្មបឋម")។

[7] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩, ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ *ឯកសារតុលាការ* E51/5/3/1 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋម")។

[8] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត, ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ *ឯកសារតុលាការ* E100 ("សំណើរបស់សហព្រះរាជអាជ្ញា")។ សំណើរបស់សហព្រះរាជអាជ្ញា ជាភាសាអង់គ្លេស និងភាសាបារាំង ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ និងសំណើជាភាសាបារាំង ត្រូវបានជូនដំណឹងថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១១។

[9] សេចក្តីសម្រេចលើសំណើសុំពន្យារពេល, ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ *ឯកសារតុលាការ* E107។

[10] សំណើរបស់ អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬ អត់ និងសំណើសុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E103។ លើចំណុចនេះ សូមមើលសារតារនីតិវិធី ពាក់ព័ន្ធនឹងសំណើសុំនានារបស់លោក អៀង សារី។

៩. មកទល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងនៅតែពុំទាន់បានធ្វើការសម្រេចលើសំណើសុំនេះនៅឡើយ។

## II. ការដេញដោល ÷ ភាពមិនអាចទទួលយកបាននៃសំណើសុំរបស់សហព្រះរាជអាជ្ញា

១០. សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបានឡើយ ហើយត្រូវតែបានបដិសេធចោលតាំងពីដំបូងទី (*in limine*)។ ជាក់ស្តែង សំណើសុំនេះត្រូវបានដាក់ "ដោយអនុវត្តនូវវិធាន ៩២ និង ៩៨ (២) នៃ វិធានផ្ទៃក្នុង"[11] ដែលវិធានទាំងពីរនេះមិនអាចអនុវត្តបានឡើយ ពោលគឺខុសអំពីវិធាន ៨៩ ដែលតាមរយៈវិធាននេះ សហព្រះរាជអាជ្ញាបានបាត់បង់សិទ្ធរបស់ខ្លួនហើយ។

១១. វិធាន ៩៨ ក្រោមចំណងជើងថា "សាលក្រម" មិនអាចត្រូវបានប្រើជាមូលដ្ឋានគតិយុត្តិសម្រាប់ឲ្យបណ្តឹងរបស់សហព្រះរាជអាជ្ញាអាចទទួលយកបាននោះឡើយ។ វិធាននោះបានចែងថា៖

> "២. សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ (...)
>
> ៣. អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថាតើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ។
>
> (...)
>
> ៧. នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះអង្គជំនុំជម្រះត្រូវសម្រេចថា គ្មានសមត្ថកិច្ចទៅលើករណីនោះទេ។

---

[11] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១។

១២. កថាខណ្ឌ ២ អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែពុំបានអនុញ្ញាតដល់សហព្រះរាជអាជ្ញាឡើយ ក្នុងការផ្លាស់ប្តូរការកំណត់បទចោទ ក្នុងដំណាក់កាលនៃការចេញសាលក្រម "ក្នុងករណីដែលមិនដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទណាមួយនោះ"។ ក្នុងដំណាក់កាលនៃការចេញសាលក្រមលើសំណុំរឿង ០០១ អង្គជំនុំជម្រះ សាលាដំបូងបានសម្រេចថា បទបញ្ញត្តិនេះបញ្ជាក់ឡើងវិញពី "ការដាក់កម្រិតដល់អំណាចក្នុងការកំណត់សាជាថ្មីនូវបទចោទ ពោលគឺការផ្លាស់ប្តូរការកំណត់បទចោទថ្មីណាមួយមិនត្រូវធ្វើឱ្យលើសពីអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់នោះទេ"[12]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបន្ថែមទៀតផងដែរថា "វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការកំណត់បទចោទ បន្ទាប់ពីពេលចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ"[13]។

១៣. បទដ្ឋាន ៥៥ នៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានលើកឡើងជាឯកសារយោង ចែងថា៖

> "១. ដោយមិនធ្វើឱ្យលើសអំពីអង្គហេតុ និងកាលៈទេសៈដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់ និងក្នុងឯកសារកែប្រែអង្គហេតុណាមួយ អង្គជំនុំជម្រះអាចធ្វើការផ្លាស់ប្តូរ តាមរយៈសេចក្តីសម្រេចរបស់ខ្លួនស្របទៅនឹងមាត្រា ៧៤ នូវការកំណត់បទចោទ ដើម្បីឱ្យអង្គហេតុមានភាពស៊ីសង្វាក់គ្នាទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងក្នុងមាត្រា (...)
>
> ២. ប្រសិនជានៅក្នុងដំណាក់កាលណាមួយនៃការជំនុំជម្រះ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់បទចោទអាចត្រូវបានផ្លាស់ប្តូរ អង្គជំនុំជម្រះត្រូវធ្វើការជូនដំណឹងដល់ភាគីនៃ នីតិវិធីអំពីលទ្ធភាពនេះ ហើយបន្ទាប់ពីបានពិនិត្យលើធាតុផ្សំនៃភស្តុតាង អង្គជំនុំជម្រះត្រូវផ្តល់លទ្ធភាព ក្នុងពេលវេលាមួយសមស្រប ដល់ភាគីក្នុងការធ្វើកំណត់សម្គាល់ផ្ទាល់មាត់ ឬជាលាយ

[12] សាលក្រមក្នុងសំណុំរឿង ឌុច, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ *ឯកសារតុលាការ* E188 កថាខណ្ឌ៤៩៤។

[13] សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៤៩៥ (មិនមានគូសបន្ទាត់ក្នុងឯកសារដើម)។

លក្ខណ៍អក្សរ (...)[14]។

១៤. នៅពេលអានវិធាន ៩៨ នៃវិធានផ្ទៃក្នុង បទដ្ឋាន ៥៥ នៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និង មាត្រា ៧៤ នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វាជាក់ច្បាស់ណាស់ថា ចៅក្រមអាចធ្វើការកំណត់បទចោទសាជាថ្មីនៅក្នុងដំណាក់កាលសវនាការលើអង្គសេចក្តី។ ការកំណត់បទចោទសាជាថ្មី ដោយយោងទៅលើការពិនិត្យភស្តុតាង អាចអនុញ្ញាតឱ្យអង្គហេតុមានភាព**ស៊ីសង្វាក់គ្នា** ទៅនឹងការកំណត់បទចោទដែលត្រឹមត្រូវបំផុត ពោលគឺការកំណត់បទចោទដែលមានលក្ខណៈត្រឹមត្រូវបំផុត ត្រូវបានកំណត់ត្រឹមត្រូវតាមច្បាប់ និងស្ថិតក្នុងយុត្តាធិការនៃសាលាជម្រះក្តី។ ក្នុងករណីផ្សេងពីនេះ សាលាជម្រះក្តីត្រូវប្រកាសយ៉ាងសាមញ្ញថា ខ្លួនគ្មានយុត្តាធិការទៅលើរឿងនេះឡើយ។

១៥. ការកំណត់បទចោទសាជាថ្មីគឺជាប្រតិបត្តិការមួយ ដែលចៅក្រមផ្តល់នូវការកំណត់ត្រឹមត្រូវចំពោះទង្វើ ឬអង្គហេតុណាមួយ ពោលគឺពុំមែនជាប្រតិបត្តិការដែលចៅក្រមអាចកែប្រែនិយមន័យគតិយុត្តិនៃបទល្មើស ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនឡើយ។

១៦. ដោយឡែក ប្រហែលជាផ្អែកទៅលើប្រតិបត្តិការក្រោយនេះហើយ ដែលសហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងសម្រេចតាមសំណើសុំរបស់ខ្លួន។ សហព្រះរាជអាជ្ញាស្នើសុំដល់អង្គជំនុំជម្រះសម្រេចអំពីច្បាប់ដែលត្រូវអនុវត្តទៅលើសាលាជម្រះក្តី ដោយស្នើសុំឱ្យអង្គជំនុំជម្រះសម្រេចអំពីបញ្ហាដែលចោទឡើងថា តើទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួមគឺជាបែបផែននៃការទទួលខុសត្រូវនៅរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ដែរឬទេ។

១៧. នៅក្នុងសាលក្រម ឌុច អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាការកំណត់បទចោទឡើងវិញអាចជាប់

---

[14] មាត្រា ៧៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ("អំពីល័ក្ខខ័ណ្ឌតម្រូវសម្រាប់សេចក្តីសម្រេច") ចែងនៅក្នុងកថាខណ្ឌ២ ថា៖ "សេចក្តីសម្រេចរបស់សភាជំនុំជម្រះ ត្រូវផ្អែកលើការវាយតម្លៃរបស់ខ្លួន លើភស្តុតាង និងដំណើរការជម្រះរឿងក្តីទាំងមូល។ សេចក្តីសម្រេច មិនត្រូវធ្វើឱ្យហួសពីអង្គហេតុ និងកាលៈទេសៈដែលបានពណ៌នានៅក្នុងបទចោទប្រកាន់ និងក្នុងការកែប្រែបទចោទប្រកាន់នានា។ តុលាការអាចផ្អែកលើសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលបានដាក់ជូន និងបានពិភាក្សានៅចំពោះមុខតុលាការ ក្នុងពេលជំនុំជម្រះប៉ុណ្ណោះ"។

ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវផ្អែកតាមវិធាន ៩៨ (២)[15]។ ដោយយោងទៅលើវិធាននេះ សហព្រះរាជអាជ្ញាយល់ឃើញថាសំណើសុំប្រភេទនេះធ្លាប់មានពីមុនមក[16]។ ផ្ទុយទៅវិញ ការអាន សាលក្រមដោយប្រុងប្រយ័ត្ន អាចឲ្យគេឈប់ជឿទៀតថាសំណើសុំបច្ចុប្បន្នរបស់ខ្លួនអាចទទួលយក បាន។

១៨. ជាក់ស្តែង អង្គជំនុំជម្រះបានធ្វើការសម្រេចសេចក្តីជាបីដំណាក់កាល។ ជាបឋម អង្គជំនុំជម្រះបានធ្វើ ការបកស្រាយវិធាន ៩៨ (២) ហើយបានធ្វើការពិនិត្យមើលថាតើការអនុវត្តវិធាននេះជាការរំលោភលើ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ដែរឬទេ[17]។ បន្ទាប់មក អង្គ ជំនុំជម្រះបានពិនិត្យមើលថាតើទ្រឹស្តី នៃសហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. ដើម្បីធានាឲ្យមានការគោរពដល់គោលការណ៍នីត្យានុកូលភាពដែរឬទេ (ដោយហេតុថាបញ្ហានេះពុំ ទាន់ត្រូវបានដកចេញពីអញ្ញត្រកម្មបឋមនៅឡើយ)[18]។ បន្ទាប់ពីបានធ្វើការឆ្លើយតបជាវិជ្ជមានទៅនឹង សំណួរទាំងពីរនេះ អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានថា ដោយផ្អែកលើធាតុផ្សំនៃភស្តុតាងដែលបាន បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ជនជាប់ចោទអាចទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈទម្រង់នៃការ ចូលរួមទៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ[19]។

១៩. វាជាក់ច្បាស់ណាស់ថា នៅពេលដែលអង្គជំនុំជម្រះធ្វើការសម្រេចអំពីភាពដែលអាចអនុវត្តបាន នៃ សហឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក. អង្គជំនុំជម្រះពុំបានផ្អែកទៅលើវិធាន ៩៨ (២) ឡើយ ប៉ុន្តែ

---

[15] សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៤៩៣។

[16] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៨។

[17] ផ្នែក ២.៧.១.៣.២ "វិធាន ៩៨ ២) នៃវិធានផ្ទៃក្នុង", សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៤៩២ ដល់កថាខណ្ឌ៥០៣។

[18] ផ្នែក ២.៧.១.៣.៣៖ "ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក", សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៥០៤ ដល់កថាខណ្ឌ៥១៣។

[19] ផ្នែក ២.៧.១.៤៖ "សំអាងហេតុទាក់ទងនឹងការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម", សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៥១៤ ដល់ កថាខណ្ឌ៥១៧។

បានផ្អែកលើគោលការណ៍នីត្យានុកូលភាព[20]។ វិធាន ៩៨ (២) ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ឡើងវិញនូវបទចោទ បន្ទាប់ពីមានការបង្ហាញនូវធាតុផ្សំនៃភស្តុតាង។

២០. ក្នុងករណីជាក់ស្តែង វិធាន ៩៨ (២) ពុំត្រូវបានអនុវត្តឡើយ គឺដូចគ្នាទៅនឹងវិធាន ៩២ ដែរ[21]។ ផ្ទុយទៅវិញ បទបញ្ញត្តិពិសេសអនុញ្ញាតឱ្យភាគីធ្វើការស្នើសុំដល់អង្គជំនុំជម្រះឱ្យធ្វើការកំណត់និយមន័យគតិយុត្តិនៃបទល្មើស ឬនៃបែបផែននៃការចូលរួម របស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែពោលគឺកំណត់អំពីច្បាប់ដែលអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ៖ ករណីនេះពាក់ព័ន្ធទៅនឹងវិធាន ៨៩ ដែលចែងអំពីអញ្ញត្រកម្មយុត្តាធិការរបស់ អ.វ.ត.ក.។ មានតែវិធាន ៨៩ និងគោលការណ៍នីត្យានុកូលភាពមួយគត់ ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើបទល្មើស និងបែបផែននៃការចូលរួមដូចដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថាតើស្ថិតនៅក្រោម ឬមិនស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួននោះ។

២១. ជាក់ស្តែង ការស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចអំពីភាពដែលអាចអនុវត្តបាននៃទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួមដោយផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានសេចក្តីថាស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចអំពីច្បាប់ដែលត្រូវអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ ហើយស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះ។ ចំណុចនេះរឹតតែមានលក្ខណៈច្បាស់លាស់ បើយើងផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ[22]។

---

[20] សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៥១២។

[21] ទោះបីជាវិធាន ៩២ អនុញ្ញាតឱ្យភាគីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ រហូតដល់ពេលបិទបញ្ចប់ការពិភាក្សាដេញដោលក៏ដោយ ក៏វិធាននេះមិនបានបញ្ជាក់ពីប្រភេទនៃសេចក្តីសន្និដ្ឋានបែបណាដែរ។ វិធាននេះ ជាបញ្ញត្តិទូទៅ ដែលត្រូវអនុវត្តនៅពេលពុំមានបញ្ញត្តិពិសេស។

[22] ឧទាហរណ៍សូមមើល៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (« TPIR »), រឿងក្តី *Karemera និងអ្នកផ្សេងទៀត តទល់នឹងរដ្ឋអាជ្ញា,* សំណុំរឿងលេខ ICTR-98-AR72.5 និង ICTR-98-AR72.6, *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ស្តីពីអញ្ញត្រកម្មយុត្តាធិការ៖ សហឧក្រិដ្ឋកម្មរួម*, ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ និង *សាលដីកាលើសុពលភាពនៃបណ្តឹង ឧទ្ធរណ៍របស់ Joseph Nzirorera ពាក់ព័ន្ធនឹងសេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីជំទាស់ទៅនឹងយុត្តាធិការតុលាការ-សហឧក្រិដ្ឋកម្មរួម*, ចុះថ្ងៃទី

២២. ជាក់ស្តែង សហព្រះរាជអាជ្ញាពុំទាន់បានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់នូវអញ្ញត្រកម្មបឋមរបស់ខ្លួនពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះក្នុងរយៈពេល ៣០ ថ្ងៃ នៅឡើយទេ ដែលបន្ទាប់ពីផុតរយៈពេលនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងចូលជាស្ថាពរ ដូចបានកំណត់ក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុង "ដែលបន្ទាប់ពីនោះ អញ្ញត្រកម្មបឋមមិនអាចទទួលយកបានឡើយ"។ ជាក់ស្តែង សំណើសុំរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ពោលគឺមានរយៈពេលជាងបួនខែក្រោយរយៈពេលផុតកំណត់ដែលចែងដោយវិធានផ្ទៃក្នុង។ ដូច្នេះសំណើសុំនោះ មិនអាចទទួលយកបានឡើយ។

២៣. ជាក់ស្តែង សហព្រះរាជអាជ្ញាមានបំណងធ្វើបណ្តឹងឧទ្ធរណ៍ "ក្លែងក្លាយ" ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម[23] ចេញដោយសហចៅក្រមស៊ើបអង្កេត។ ពាក្យបណ្តឹងឧទ្ធរណ៍ក្លែងក្លាយនេះ គឺជាពាក្យដែលសហព្រះរាជអាជ្ញាធ្លាប់ប្រើប្រាស់ នៅពេលដែលខ្លួនធ្វើការសន្និដ្ឋានថា "អង្គបុរេជំនុំជម្រះបានប្រព្រឹត្តកំហុសឆ្គងផ្លូវច្បាប់នោះ[24]"។

២៤. ដោយឡែក សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា (វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង)។ សហព្រះរាជអាជ្ញាក៏បានទទួលស្គាល់ចំណុចនេះផងដែរ ដោយបានលើកឡើងកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ក្នុងសវនាការសម្រេចអំពីការដោះលែងឲ្យនៅក្រៅឃុំ ថា៖

---

១៤ ខែ តុលា ឆ្នាំ ២០០៥ កថាខណ្ឌ៩។ នៅក្នុងសាលដីកានេះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា បញ្ហាពាក់ព័ន្ធនឹងការអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខតុលាការ គឺជាអញ្ញត្រកម្មបន្ទាន់បង្ខំ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Enver Hadzihasanovic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-01-47-AR72, *សេចក្តីសម្រេចលើអញ្ញត្រកម្មយុត្តាធិការ (ការទទួលខុសត្រូវរបស់ថ្នាក់លើ)* សំណុំរឿងលេខ IT-01-47-AR72, ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣។ នៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក៏បានសម្រេចថា ទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុង ច្បាប់ទំនៀមទំលាប់អន្តរជាតិ គឺស្ថិតក្នុងបញ្ហាយុត្តាធិការ។

[23] សាលដីការបស់អង្គបុរេជំនុំជម្រះ។

[24] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៣១។

"សំណើសុំនេះមិនអាចទទួលយកបានឡើយ ដោយហេតុថាសំណើសុំនេះបានស្នើសុំឱ្យអង្គសវនាការធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ហើយស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការកំណត់អំពីសុពលភាពនៃសេចក្តីសម្រេចនេះ ដែលចេញថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

វិធានផ្ទៃក្នុងរបស់តុលាការ នៅត្រង់វិធាន៧៧ (១៣) បានចែងយ៉ាងច្បាស់ថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយគេពុំចាំបាច់ធ្វើការបញ្ជាក់នៅទីនេះថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានបង្កើត ក្នុងក្របខណ្ឌនៃវិធានផ្ទៃក្នុង ឱ្យដើរតួនាទីជាសាលាឧទ្ធរណ៍នោះទេ។ យើងសូមប្រកាសថា ទោះបីជាមានការយល់ឃើញថា ទឡ្ហីករណ៍ដែលលើកឡើងដោយ នួន ជា មានតម្លៃយ៉ាងណាក៏ដោយ ក៏សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនអាចត្រូវបានពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូងដែរ ហើយអង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការក្នុងរឿងនេះទេ[25]"។

២៥. ម្យ៉ាងទៀត លោក ខៀវ សំផន មានបំណងចង់រំលឹកថា ទម្រង់នៃការទទួលខុសត្រូវបែបសហឧក្រិដ្ឋកម្មរួមត្រូវបានលើកឡើងជាញឹកញាប់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ សញ្ញាណនេះត្រូវបានលើកឡើងចុងក្រោយដោយក្រុមមេធាវីការពារក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយ[26]។ សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបថា៖ "ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចលើកឡើងទៀតអំពីបញ្ហា (...) សហឧក្រិដ្ឋកម្មរួម ថាជាបែបផែននៃការចូលរួមក្នុងការប្រព្រឹត្តិបទល្មើសឡើយ។ អង្គបុរេជំនុំជម្រះបានស្តាប់ និងសម្រេចអំពីបញ្ហានេះរួចហើយ។ បើផ្អែកលើអាជ្ញាអស់ជំនុំ អំណះអំណាងនៃ

[25] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសំណើសុំឱ្យដោះលែង "នួន ជា, អៀង ធីរិទ្ធ និង ខៀវ សំផន" ជាបន្ទាន់ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ *ឯកសារតុលាការ* E1/1.1 ទំព័រ ៤៧ ចាប់ពីបន្ទាត់ ៩ ដល់ ២៥ [លេខទំព័រក្នុងប្រតិចារឹកជាភាសាបារាំង] មិនមានគូសបន្ទាត់ពីក្រោមនៅក្នុងឯកសារដើម។

[26] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ២០ ខែ តុលាឆ្នាំ ២០១០ *ឯកសារតុលាការ* D427/1/6 កថាខណ្ឌ២៤៩-២៦៣។

បណ្តឹងឧទ្ធរណ៍ចំណុច ១ និង ៩ ត្រូវតែបានបដិសេធចោល[27]"។ ពុំមានអ្វីដែលអាចពន្យល់បាន ខណៈដែលសហព្រះរាជអាជ្ញាលើកឡើងនូវបញ្ហាដដែលនេះឡើងវិញរយៈពេលប៉ុន្មានខែក្រោយមក។

២៦. បញ្ហាទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានចាត់ទុកថាជាទម្រង់នៃការទទួលខុសត្រូវមួយ ក៏ត្រូវបានលើកឡើងផងដែរដោយមេធាវីការពារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុវត្តនូវវិធាន ៨៩ នៃវិធាន ផ្ទៃក្នុង[28] ហើយសហព្រះរាជអាជ្ញាបានធ្វើឱ្យបាត់បង់នូវសិទ្ធិក្នុងការឆ្លើយតបរបស់ខ្លួន[29]។ បញ្ហានេះ បច្ចុប្បន្ន ត្រូវបានព្យួរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអង្គជំនុំជម្រះសាលាដំបូងពុំបានតម្រូវឱ្យភាគីធ្វើការដាក់នូវទឡ្ហីករណ៍ថ្មីឡើយ។ សហព្រះរាជអាជ្ញាមិនអាចរំលងវិធាន ៨៩ ហើយពឹង ផ្អែកលើសំណើសុំបច្ចុប្បន្នរបស់ខ្លួន ដើម្បីលើកឡើងនូវទឡ្ហីករណ៍នានាសំដៅបំពេញបន្ថែមនូវចម្លើយ តបរបស់ខ្លួន បន្ទាប់ពីផុតរយៈពេលក្នុងការដាក់ចម្លើយតប និងដោយរំលោភលើការដាក់កម្រិតចំនួន ទំព័រនោះ។

២៧. លោក ខៀវ សំផន នឹងមិនធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍ថ្មីៗដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលទៅក្នុងសំណើសុំរបស់ខ្លួនដែលមានលក្ខណៈមិនអាចទទួលយកបាននោះឡើយ ហើយអង្គជំនុំជម្រះមិនត្រូវស្តាប់ហេតុផលឡើយ នៅពេលដែលសំណើសុំនោះលើកឡើងអំពីអញ្ញត្រកម្មបឋមនោះ។

---

[27] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ *ឯកសារតុលាការ* D427/3/6 កថាខណ្ឌ១១ និង កថាខណ្ឌ៤៥ ដល់ កថាខណ្ឌ៥១។

[28] អញ្ញត្រកម្មរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ *ឯកសារតុលាការ* E44 កថាខណ្ឌ៣៣ ដល់ កថាខណ្ឌ៣៨។

[29] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋម, កថាខណ្ឌ២២-២៦។

## ហេតុដូច្នេះ

២៨. មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- **ប្រកាសថា** សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន
- ក្នុងគ្រប់ករណីទាំងអស់ **មិនស្តាប់**នូវរាល់ទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសំណើសុំរបស់សហព្រះរាជអាជ្ញា នៅក្នុងពេលដែលអង្គជំនុំជម្រះពិនិត្យទៅលើអញ្ញត្រកម្មបឋមនោះ។

### រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

### និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | [signature] |
| P. | មេធាវី Jacques VERGÈS | ប៉ារីស | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |